# បណ្ដាំពាលី

១.សូមសម្ដែងសារស័ព្ទច្បាប់សៃយភេទ     នៃចមពង្សពានរេស[1]រឿងសាណាម[2]
ក្បៀវក្លាក្មែងស្មែងស្អាត់បទសង្ក្រាម     ទ្រង់ព្រះនាមរាជាឈ្មោះពាលី។
២.ជាបុត្រអង្គអម្រិន្ទ្រពិនលោកីយ     គ្រងខាសខឹមបុរីរាជធានី
ល្បីល្បុះគ្រប់ភពផែនដែនបបរី     ទាំងទិសទីទ្វីទ្វីបសឹងខ្លាចក្រែង។
៣.ទាំងទេវាយក្សយង់ទ្រង់អំណាច     ឮតែនាមខ្ញបខ្លាចស្មោស្ញប់ស្ញែង
រអាអស់មិនអាចចេញអង្គទែង     ព្រះអង្គឯងពូជវង្សពង្សឥន្ទ្រា។
៤.កាលត្រូវសរព្រហ្មាសប្ញទ្ធីក្រៃ     ទ្រង់យកដៃចាប់ជាប់ដោយឫទ្ធា
មិនឱ្យមុតមានឈាមស្នាមអង្គា     និងឱ្យស្ញែងនាមាទូទ្វីបា។
៥.ទុកជាច្បាប់សម្រាប់នាយទាហាន     ត្រិះផ្សោគ[3]ផ្សានធ្វើតាមទៅមុខណា
ព្រះហត្ថស្ដាំទ្រង់ក្ដាប់ចាប់សរថ្វា     ព្រះហត្ថាឆ្វេងក្សត្រទ្រង់បោយហៅ។
៦.ទៅសុគ្រីពសូរីវង្សពង្សសូរិយា     និងអង្គតបុត្រារត្នឆោមឆៅ
ប្អូនើយចូលមកអាយបងប្រដៅ     ត្បិតអង្គចៅនឹងជាខ្ញុំព្រះចក្រី។
៧.ខំគ្រងវង្សឱ្យគង់ជាច្បងច្បាស់     យកតេជះតម្កល់លើកេសី
បាយកសុចរិតភក្ដី     ជីវិតវៃថ្វាយក្រោមព្រះបាទា។
៨.មួយបើបាចូលគាល់ដល់ទ្វាររាំង     បាឈប់តាំងប្រណម្យនាមកេសា[4]
រំលឹកគុណបុន្យបាទមូលីកា     សឹមយាត្រាកាន់ផ្ទៃព្រះរោងទ្រង់។
៩.កាលបាគង់ចាំគាល់ក្នុងនិវេស     កុំធ្វេធ្វេសប្រហែសប្រាណលើសលង់
ក្រែងជួនស្ដេចត្រាច់ត្រង់មកយល់យង់     រវាំងអង្គឱនខ្លាចព្រះអាជ្ញា។

[1] ចំណុចសំខាន់នៅត្រង់នេះគឺគេប្រើអក្សរ«គ» ត្រឹមត្រូវហាក់ដូចជានៅសម័យបុរាណដែរ។

[2] អំណើះតទៅកាលណាអ្នកអានឃើញពាក្យណាដែលមានសញ្ញាផ្កាយ(*) នៅជាប់ជាមួយនោះមានន័យថាជាពាក្យឬកន្សោមពាក្យដែលខ្ញុំពុំស្គាល់ ឬពុំយល់ន័យ។

[3] មកពីពាក្យ«ឧទ្យោគ»ប្រែថាខិតខំ។

[4] ប្រហែលគេចង់ថា«ប្រណម្យនមស្ការ»។

១០.ធ្វើជាខ្ញុំសម្គាល់កៃលាសស្ថាន[5] ទើបបានតាមព្រះទ័យទ្រង់ប្រាថ្នា
បើត្រាស់សួរមកចំសឹមចរចារ រិះត្រិះត្រាឱ្យត្រូវទំនងន័យ។
១១.ចូលគាល់កុំតែងអង្គឱ្យពទ្រោយ ហាក់ពាយផាយផ្ទឹមនិងអង្គជៀសជ័យ
កុំទូលទាស់ផ្ទុញផ្ទាន់ព្រះហឫទ័យ កុំសម្លឹងនេត្រនៃព្រះចក្រា។
១២.រីព្រះចមចក្រពង្សជាវង្សនារាយណ៍ ព្រះប្រាជ្ញាធ្ងុះធ្លាយដូចរត្នា
កុំបាហក់ហួសជ្រួសរាជការ រិះត្រិះត្រាឱ្យត្រូវចិត្តមហាជន។
១៣.បើនរណាកាចបាធ្វើក្អៃតាមកាច នរណាខ្លាចស្វែងផលឱ្យគិតគន់
ជាជញ្ជីងជញ្ជឹងថ្លឹងចិត្តជន ខាងណាធ្ងន់លន់លប់លាក់លោះលៃ[6] ។
១៤.មួយស្នេហ៍ស្នំសមសក្តិអគ្គនារី ទោះជាទីចម្រើនរ័កហឫទ័យ
កុំបាបែរបាយបៀងមៀងមើលមៃ ព្រះជៀសជ័យទតយល់ពិភាល់បា។
១៥.ទាំងទាសីនៃអ្នកអគ្គនារី ទោះឆវីល្អស្មើកន្និរណា
កុំប្អូនប្អូកលូកលលួងស្នេហ៍[7] ប្រៀបចិន្តាថាជាស្នំបវរ។
១៦.របស់អ្វីហឫទ័យទ្រង់ស្ម័គ្រស្មោះ ថែរបស់នោះទុកតាំងភូធរ
បទណាហាមប្រាមចិត្តកុំគិតល នឹងសាទរទុកតាមជាខ្ញុំវៃ។
១៧.បើទ្រង់ប្រោសកុំធ្លើលលើខ្លាំង រិះរវាំងក្រោយមុខខ្លាចទុក្ខភ័យ
កុំកាចកោងប៉ោងយ៉ៃធំ[8] ពេកនៃ កុំគួនគៃគិតក្រោធតបក្សត្រា។
១៨.បាថ្នមយសឱ្យសមពហុសក្តិ កុំហ៊ឹកហ៊ាក់ឱ្យហួសពីវាសនា
ស្លៀកប្រដាប់ឱ្យសមនឹងកាយា កុំយាត្រាគន់កាយឆ្វេងស្តាំផ្សំ។
១៩.មួយមានភៀនភក្តិកុំខ្ញុំរាជការ នឹងស្រឡាញ់ជាគ្នារើសឱ្យសម
បើត្រង់ៗស្នងសងអារម្មណ៍ បើវៀចៗឱ្យសមឱ្យសួនការ។

---

[5] សម្រួលពាក្យក្នុងការស្មានទៅឡើយ។ពាក្យដែលចម្លងមកគេសរសេរថា៖«ធ្វើរជាខ្ញុំមសំមគោលកលស្ថាន»។

[6] ពាក្យក្នុងឃ្លានេះប្រហែលខ្វះជាពាក្យប្រើក្នុងការថ្លឹងជញ្ជីង។

[7] ត្រង់នេះបើដាក់ជា«ស្នេហាទើបជួន»។

[8] «យ៉ៃ» ជាពាក្យសៀមប្រែថា«ធំ»ដែរ។

២០.បើបង់សីលរិះគិតថ្មិតថ្មមសក្តិ    កុំហ៊ឹកហ៊ាក់ឱ្យហួសពីវាសនា
បើគប់ពាលគិតលុបបង់* ពាលណា    គិតប្រហារពាលកាចឱ្យខ្លាចក្រែង។
២១.បើគេល្អស្មើចិត្តកុំគិតកាច    បើគេខ្លាចឱនយសកុំកំហែង
កុំនាំភឿនដើរលេងជាអ្នកល្បែង    ឱ្យសង្វែបចិត្តគិតក្រែងព្រះបេស្កា។
២២.មួយបើត្រូវរាជទណ្ឌដល់ពាន់ដង    កុំបាចង់គំនុំគុំក្សត្រា
កុំប្រែចិត្តគិតក្បត់ព្រះចក្រា    ខំឧស្សាហ៍ស្វែងផលឱ្យយោងខ្លួន។
២៣.មួយបាគាល់នាឆ្ពោះព្រះភក្ត្រា    កុំប្រែក្រោយចរចារមិនសមសួន
នៅនាព្រះទីនាំងរាំងខ្លួន    បាគាល់គួនចាំស្តាប់រាប់បញ្ជា។
២៤.បើទ្រង់ព្រះក្រោធក្រៃ នឹងមន្ត្រី    កុំស៊ិយសែមថែមស្តីឱ្យក្រោធា
ទោះកិច្ចការសារពើផងនានា    កុំពិតទូលគាល់គ្រាទ្រង់ព្រះខ្ញាល់។
២៥.មើលទំនងល្មមទូលសឹមទូលពិត    បាពិនិត្យក្នុងក្រៅគ្រប់អម្បាល
មើលព្រះទ័យប្រីយប្រឹមប្រោសក្រសាល    មិនទ្រង់ខ្ញាល់សឹមយកសេចក្តីថ្លែង។
២៦.បើត្រាស់សួរប៉ុន្មានទូលប៉ុណ្ណោះ    ពាក្យក្រៅនោះកុំយកមកផ្ទើសផ្ទែង
តែស្តីច្រើនជ្រុលមាត់ភ្ញាត់ខ្លួនឯង    ពាក្យដែលស្តែងគេមិនស្តាប់អាប់អង្គបា។
២៧.មួយព្រះហរីរក្សចក្រពេជ្រ    ប្រោសព្រះទាន[9]បំណាច់ពលសេនា
ដែលប្រាកដប្រកបធបរាជការ    កុំប្ញស្យាទូលទាស់អធ្យាស្រ័យ។
២៨.របស់អ្វីឈ្មោះថាព្រះរាជទ្រព្យ    បាគ្នេគ្នែគែរាប់រិះសព្វថ្ងៃ
ទោះតិចតួចហោចស្តួចទុកសំបៃ    យកចិត្តគិតអាល័យដូចផងខ្លួន។
២៩.បើមានអ្នកប្រទេស[10]ដទៃមក    កុំបៀតយកមកជាមិត្តភក្តិស្ងួន
តែជ្រាបដល់នឹងកើតអំពល់ខ្លួន    បាគិតអ្វីឱ្យមួនកុំឱ្យហ្មង។
៣០.មួយកាលចោមចក្រពង្សហរិរក្ស    ស្តេចចុះកាន់ដំណាក់ឈួន* ផែផង
សឹងព្រំដោយរាជរថសមស្នេហ៍ស្នង    កុំផ្អៀងផ្អងមើលមៀងបៀងបាយបែរ។

[9] ពាក្យនេះហើយដែលក្លាយមកជា«ប្រធាន»។

[10] ដើម«ស»នៅទីនេះក៏គេសរសេរជា«គ»។ ត្រឹមត្រូវតាមសំស្ក្រឹតដូចនៅបុរាណកាលដែរ។

*៣១.ស្ថានណាទ្រង់ព្រះបញ្ញត្តហាម　　បាប្រាប់ប្រាមចិត្តចាំតាមក្រសែ*
*កុំភ្លើនភ្លេចឱ្យភ្ញាត់បត់បាទបែរ　　បាគិតកែឱ្យគង់បណ្ដាំមុនី។*
*៣២.វេលាមានទាក់ទាមសង្គ្រាមសឹក　　កុំបាភ្ញឹកឱ្យភ្ញាក់ផ្អើលយោធី*
*ចូលបាគិតកែកុនកលភេរី　　រកទិសទីតាំងតែងឱ្យសះង៉ារ*។*
*៣៣.នឹងប្រព្រឹត្តិគិតការសង្គ្រាមជ័យ　　ឱ្យរាំងវៃវេះវាត់ស្ទាត់កលការ*
*យល់ទ្រោមទ្រុឌកុំទ្រាំឱ្យចោមណា　　បើគេគង់ក្បៀងក្លាបាបោះទល់។*
*៣៤.បាថ្នមចិត្តពលផងឱ្យស្នេហា　　នឹងគិតការស្វែងហេតុឱ្យឃើញផល*
*សព្វឧបាយស្រាយដោះឱ្យដឹងដល់　　មានការកលគិតកែឱ្យអាចហាន។*
*៣៥.ទាំងនេះហើយតែដោយព្យាយាមពិតកុំគិតខ្ជិលប្រើគេតាងភ្នែកប្រាណ*
*ជាចមទ័ពរំង៉ាប់ចិត្តក្រោធក្លាន　　នឹងហ៊ានខ្លាចក្លាហានឱ្យល្មមល្អ។*
*៣៦.កុំអួតបេះរិះរត់តែទីង៉ាយ　　ទីណាធ្ងាយបាយកកាយតាំងត*
*ជាជាតិប្រុសធ្វើទ័ពទុកនាមករ　　ឱ្យល្បើល្បះល្បីខ្ចរទូលោកា។*
*៣៧.ចូលបែបយ៉ាង* បងមានសច្ចំ[11]　　មិនគិតទាំងជីវិតប៉ុនកេសា*
*មិនគួរស្លាប់គួរស្ដាយដួងជីវា　　មិនគួរសូន្យសង្ខារកុំអាល័យ*
*៣៨.បងសូមផ្ញើកែវតាពាយុផាក់*　　ចូររួមរ័កស្ម័គ្រស្មោះកុំអារថ្បៃ*
*គ្រងរក្សាគ្នាទៅនៅក្រុងក្រៃ　　ទាំងក្របីស្រីកំហែងហនុមាន។*
*៣៩.ចូរបាជួយសង្គ្រោះសព្វសូរិយវង្ស　　នៅពីពង្សអង្គក្នួយទាំងពីរប្រាណ*
*ផ្ដាំស្រេចស្ដេចលែងសរព្រះអវតាន[12]　　សង្ខារប្រាណបានទៅកើតសួគ៌ា។*
*៤០.ទើបបានទេវាថាពាលី　　ព្រោះមានទីសច្ចំជាសព្វគ្រា*
*និងតេជះសរព្រះនារាយណ៍ជួយនាំពារ　　បានសោយសុខសួគ៌ាសម្រានចិត្ត។*
*៤១.សុភាសិតពាលីពីបុរាណ　　នោះចំណានមែនហើយតែក្រគិត*

---

[11] *ត្រង់នេះប្រហែលជាពាលីនិយាយពីខ្លួនឯងដែលសុខចិត្តស្លាប់ដោយមិនព្រមឱ្យព្រះរាមទុកជីវិតខ្លួនដោយដកយកសរព្រហ្មាសចេញ។ សូមអានជំពូកទី៣, លេខរៀងទី៤៨។*

[12] *«អវតារ» ជាតាមមាត់សៀម*

សាធុជនច្រើនទុញទាល់គំនិត ខំពិនិត្យគ្រាន់ផាយពិចារណា។
៤២.ខ្ញុំជាម៉ឺនឈ្មោះមាសឈ្វាសឆ្មៀតគិត ចង់លិខិតប្រឹតប្រែកេរ្តិ៍លេខា
ទុកជាច្បាប់សម្រាប់ខ្ញុំរាជការ មិនវិត្ថារព្រោះទើបរើបរឹកសន់* ។[13]
៤៣.ទោះបើខុសទោះបើខាតបាទបទក្តី សូមប្រណីជួយគិតកែប្រែសន្ទន់
ឱ្យតែត្រង់ឱ្យតែត្រូវខះណះក្ងន* ទុកជាបែបគ្រាន់ជាបន់-បណ្តាំអើយ។

[13] នៅត្រង់នេះម៉ឺនមាសឱ្យថ្ងៃខែ ដោយសរសេរតាមរបៀបសម័យនោះ។ បើសរសេរតាមឥឡូវនេះគឺ« ថ្ងៃអង្គារ៍ ១កើតខែស្រាព»។